ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

# លិខិតអបអរសាទរ

## ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## នៅក្នុងឱកាសទទួលគោរមងារកិត្តិយសពិសេស នៃរាជបណ្ឌិត្យសភាកម្ពុជា
## "កិត្តិទេសាភិបាលបណ្ឌិត"

**ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ជាទីស្រលាញ់រាប់អាន!**

នៅក្នុងឱកាសដ៏មហាឧត្តុង្គឧត្តមប្រសើរថ្លៃថ្លា ប្រកបដោយក្តីសោមនស្សរីករាយ ខ្ញុំសូមចូលរួមអបអរសាទរ យ៉ាងត្រៀវត្រាចំពោះ**ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត** ដែលត្រូវបាន **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ត្រាស់បង្គាប់ផ្តល់គោរមងារកិត្តិយសពិសេសដ៏ឧត្តុង្គឧត្តមបំផុត នៃរាជបណ្ឌិត្យសភាកម្ពុជា ជា "**កិត្តិទេសាភិបាលបណ្ឌិត**"។

ការទទួលគោរមងារកិត្តិយសពិសេសដ៏ឧត្តុង្គឧត្តមបំផុត "**កិត្តិទេសាភិបាលបណ្ឌិត**"នេះ ជាការទទួលស្គាល់នូវស្នាដៃ **ឯកឧត្តម កិត្តិទេសាភិបាលបណ្ឌិត** ដែលមានគុណបំណាច់ និងស្នាដៃដ៏ត្រចះត្រចង់ ក្នុងនាមជាយុវជនជំនាន់ថ្មី និងជាឥស្សរជនដឹកនាំដ៏ឆ្នើមរបស់ព្រះរាជាណាចក្រកម្ពុជា ដែលពោរពេញទៅដោយសមត្ថភាព និងទេពកោសល្យខ្ពស់ ព្រមទាំងមានគុណធម៌ សីលធម៌ ព្រហ្មវិហារធម៌ ពិសេសបាននិងកំពុងដឹកនាំធ្វើសកម្មភាពជាគំរូជាក់ស្តែងជាច្រើនឆ្នាំមកហើយលើវិស័យសំខាន់ៗ ដើម្បីបុព្វហេតុ **ជាតិ សាសនា** និង **ព្រះមហាក្សត្រ** ។

នៅក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនៈត្រ័យ វត្ថុស័ក្តិសិទ្ធិក្នុងលោក និងទេវតាតាមជួយបីបាច់ថែរក្សាប្រទានពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរ គ្រប់ប្រការជូនចំពោះ **ឯកឧត្តម កិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត និងលោកជំទាវ** ព្រមទាំងបុត្រាបុត្រីជាទីស្រលាញ់ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម កិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

ថ្ងៃពុធ ៨រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣

**សម្តេចពិជ័យសេនា ទៀ បាញ់**